**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខ: ០៤៧ ស.ជ.ណ / គ.ជ.អ.ប

ថ្ងៃសុក្រ ៦រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០២០

## គោរពជូន

## ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលខេត្ត

**<u>កម្មវត្ថុ</u>**៖ ស្តីពីការបែងចែកការទទួលខុសត្រូវរបស់មន្ត្រីសុវត្ថិភាពបរិស្ថាន និងសង្គម ដើម្បីជួយពិនិត្យនិងផ្តល់យោបល់បច្ចេកទេសសុវត្ថិភាពបរិស្ថាន និងសង្គម ក្នុងគម្រោងមូលនិធិឃុំ សង្កាត់ ក្រុង ស្រុក និងរាជធានី ខេត្ត។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ មេត្តាជ្រាបថា កន្លងមកលេខាធិការដ្ឋាន គ.ជ.អ.ប. បានចាត់តាំងមន្ត្រីចំនួន០២រូប អោយទទួលបន្ទុកគាំទ្រលើការពិនិត្យការងារសុវត្ថិភាពបរិស្ថាន និងសង្គម របស់រដ្ឋបាលថ្នាក់ក្រោមជាតិនៃខេត្តទាំង២៤។ ក្រោយពីបានពិនិត្យមើលពីទំហំការងារនេះ លេខាធិការដ្ឋាន គ.ជ.អ.ប. បានរៀបចំចាត់តាំងទីប្រឹក្សា និងមន្ត្រីចំនួន០៣រូប អោយទទួលបន្ទុកគាំទ្រលើ កិច្ចការពិនិត្យការងារសុវត្ថិភាពបរិស្ថាន និងសង្គម ចាប់ពីថ្ងៃទី **០១ ខែ មិថុនា ឆ្នាំ២០២០** ដូចមាន ឈ្មោះខាងក្រោម៖

១. លោក **មុំ រចនាវិសនាជាតិ** អនុប្រធានការិយាល័យ គាំទ្រសេវាបច្ចេកទេសទូទៅ នៃអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី ទទួលបន្ទុកគាំទ្រការងារសុវត្ថិភាពបរិស្ថាន និងសង្គម ចំនួន០៥ខេត្ត រួមមាន ៖**ខេត្តកំពង់ចាម កណ្តាល រតនគិរី ស្ទឹងត្រែង និងកំពង់ធំ** ។

<u>ទូរស័ព្ទលេខ:</u> ០១២ ៩១៩ ៤០៤

២. លោក **ស សុមុន្នីរតនៈ** អនុប្រធានការិយាល័យ គាំទ្រសេវាបច្ចេកទេសទូទៅ នៃអង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធី ទទួលបន្ទុកគាំទ្រការងារសុវត្ថិភាពបរិស្ថាន និងសង្គមចំនួន០៥ខេត្ត រួមមាន៖ **ខេត្តត្បូងឃ្មុំ ប៉ៃលិន សៀមរាប បន្ទាយមានជ័យ និងឧត្តរមានជ័យ** ។

<u>ទូរស័ព្ទលេខ:</u> ០៧៨ ៩៧៦ ៧៦៩

៣. លោក **តេ រិទ្ធី** ទីប្រឹក្សាសុវត្ថិភាពបរិស្ថាននិងសង្គម នៃអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី ទទួលបន្ទុកគាំទ្រការងារសុវត្ថិភាពបរិស្ថាន និងសង្គមចំនួន១៤ខេត្ត រួមមាន៖ **ខេត្តកំពង់ឆ្នាំង មណ្ឌលគិរី ព្រៃវែង ស្វាយរៀង កោះកុង កំពង់ស្ពឺ កែប កំពត តាកែវ ពោធិ៍សាត់ បាត់ដំបង ក្រចេះ ព្រះសីហនុ និងព្រះវិហារ**។

<u>ទូរស័ព្ទលេខ:</u> ០១២ ៧៥៨ ០០៣

អ៊ីមែលសម្រាប់ទំនាក់ទំនងក្រុមការងារបច្ចេកទេសសុវត្ថិភាពបរិស្ថាន និងសង្គមប្រចាំលេខាធិការដ្ឋាន គ.ជ.អ.ប៖ safeguardteam@ncdd.gov.kh

**សូមបញ្ជាក់៖** ក្រុមការងារSafeguardប្រចាំខេត្តនីមួយៗ សូមដាក់ឈ្មោះខេត្តរាល់ពេលផ្ញើរឯកសារគម្រោងមូលនិធិឃុំ សង្កាត់ ស្រុក ក្រុង រាជធានី និងខេត្ត ដើម្បីងាយស្រួលដល់ក្រុមការងារបច្ចេកទេសសុវត្ថិភាពបរិស្ថាន និងសង្គមប្រចាំលេខាធិការដ្ឋានគ.ជ.អ.ប.ទទួលបន្ទុកខេត្តនីមួយៗ ជួយពិនិត្យ និងផ្តល់យោបល់បច្ចេកទេសជូន។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាប និងចាត់ចែងតាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ** ទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប.**

លេខាធិការដ្ឋាន

**ខ៉ាន់ ចំរើន**